Disability Rights California

*បណ្ដាញការពារ និង គាំទ្រនៃរដ្ឋកាលីហ្វ័រញ៉ា (California)*

អាស័យដ្ឋានគេហទំព័រ: www.disabilityrightsca.org

ទូរស័ព្ទឥតគិតថ្លៃ: (800) 776-5746

TTY: (800) 719-5798

---

**# 3: អត្ថន័យសំខាន់ៗស្ដីពីការកាត់ខ្ទង់ថវិកានៃរដ្ឋ (Fact Sheet) សម្រាប់កម្មវិធីផ្ដល់អត្ថប្រយោជន៍នានា – ថ្ងៃទី6 ខែសីហា ឆ្នាំ2009**

## អត្ថប្រយោជន៍ពីកម្មវិធី SSI នឹងត្រូវគេកាត់ផ្ដាច់សារជាថ្មីទៀត

នៅថ្ងៃទី1 ខែតុលា នឹងមានការកាត់ផ្ដាច់បន្ថែមទៀតនៅកម្មវិធីសុវត្ថិភាពប្រាក់ចំណូលបន្ថែម/ការទូទាត់បំពេញបន្ថែមរបស់រដ្ឋ (SSI/SSP)។ លិខិតអំពីការព្យាយាមនេះ សង្ខេបជូនអំពីខ្លឹមសារនៃការកាត់ផ្ដាច់អត្ថប្រយោជន៍នេះ។

**តើច្បាប់នេះ បានប្រែប្រួលយ៉ាងដូចម្ដេច?**

នៅថ្ងៃទី1 ខែតុលា ឆ្នាំ2009 ខាងមុខនេះ អត្រាទូទាត់អត្ថប្រយោជន៍នៃកម្មវិធី SSI/SSP នឹងត្រូវគេកាត់ចំនួន$5 សម្រាប់បុគ្គលទាំងឡាយណាដែលមានលើសពី65ឆ្នាំ ឬ មានពិការភាព។ អត្រានៃការទូទាត់ នឹងត្រូវគេកាត់ចំនួន$82 សម្រាប់គ្រួសារប្ដីប្រពន្ធទាំងអ្នកដែលមានអាយុលើសពី65ឆ្នាំ ឬ មានពិការភាះ។ ការកាត់ទាំងនេះគឺស្ថិតលើការបន្ថែមចំពោះការនានាដែលត្រូវបានគេធ្វើរួចហើយនៅថ្ងៃទី1 ខែឧសភា ឆ្នាំ2009 និង ថ្ងៃទី1 ខែកក្កដា ឆ្នាំ2009។

ការកាត់បន្ថែមទាំងនេះ ដូចការកាត់កន្លងមកនានាដែរ បានកើតចេញពីថវិការដ្ឋនៃរដ្ឋកាលីហ្វ័រញ៉ា។[1] ការកាត់ទាំងនេះ បានចូលជាធរមានដោយច្បាប់និតិបញ្ញត្តិ និង ទទួលបានការយល់ព្រមបញ្ជាក់ដោយអភិបាលរដ្ឋកាលីហ្វ័រញ៉ា។ ដូចគ្នាទៅនឹងការកាត់ផ្សេងៗទៀតដែរនោះ វាជាចំណែករបស់រដ្ឋ មិនមែនចំណែករបស់សហព័ន្ធទេដែលកំពុងត្រូវបានគេកាត់។

ផ្នែករដ្ឋបាលសន្តិសុខសង្គម (SSA) បានបញ្ជូនចេញនូវសេចក្តីជូនដំណឹងដែលប្រាប់ដល់អ្នកទទួលអត្ថប្រយោជន៍អំពីការកាត់ទុកជាមុន មានន័យថា SSA នឹងបញ្ជូនសេចក្តីជូនដំណឹងអំពីការកាត់ដែលប្រហែលជានៅថ្ងៃទី1 ខែតុលា ឆ្នាំ2009 ជាដើម។ SSA មានទំនួលខុសត្រូវចំពោះការបញ្ជូនចេញនូវសេចក្តីជូនដំណឹង ដោយសារ SSA គ្រប់គ្រងលើកម្មវិធី SSI/SSP។

## តើខ្ញុំ នឹងទទួលបានអត្ថប្រយោជន៍ប៉ុណ្ណាពីកម្មវិធី?

កម្រិតអត្ថប្រយោជន៍ SSI/SSP សម្រាប់បុគ្គលម្នាក់ៗ និង គូស្វាមីភរិយា រហូតមកទល់ពេលនេះ ត្រូវបានគេកាត់ជាច្រើនដងរួចមកហើយនៅឆ្នាំនេះ។ តារាងទី1ខាងក្រោមនេះ ប្រាប់នូវព័ត៌មានលម្អិតជាផ្នែកៗនៃអត្រា ឬ កម្រិតអត្ថប្រយោជន៍ដែលកាត់សម្រាប់បុគ្គលម្នាក់ៗ។ តារាងទី2 ប្រាប់អំពីលម្អិតជាផ្នែកៗសម្រាប់អ្នកមានប្តីប្រពន្ធ។ **នៅកូនឡោនចុងក្រោយនៃតារាងនេះ ដែល**

[1] វិសោធនកម្មច្បាប់ទាំងនេះ គឺជាផ្នែកនៃកិច្ចប្រជុំពិភាក្សាច្បាប់របស់ព្រឹទ្ធសភាពលើកទី4ឆ្នាំ2009 (Senate Bill 4, 2009) សម័យប្រជុំវិសាមញ្ញលើកទី4។

**សរសេរជាអក្សរដិតច្បាស់ៗ ពន្យល់ប្រាប់អំពីកម្រិតអត្ថប្រយោជន៍ដែលនឹងមាននៅថ្ងៃទី1 ខែតុលា ឆ្នាំ2009។**[2]

| **អត្រាទូទាត់សម្រាប់កម្មវិធីSSI/SSP—បុគ្គលដែលមានសិទ្ធិ** | | | | | |
|---|---|---|---|---|---|
| | 1ធ្នូ 2008 | 1មករា 2009 | 1ឧសភា 2009 | 1កក្កដា 2009 | **1តុលា 2009** |
| ជនចាស់ជរា ឬ ពិការដែលរស់នៅផ្ទះ | $870 | $907 | $870 | $850 | **$845** |
| ជនពិការភ្នែកដែលរស់នៅផ្ទះ[3] | $935 | $972 | $935 | $913 | **$908*** |
| ក្មេងអាយុក្រោម18ឆ្នាំ[4] ដែលរស់នៅផ្ទះ | $756 | $793 | $756 | $739 | **$737*** |
| អ្នករស់នៅផ្ទះដោយគ្មានលទ្ធភាពធ្វើអាហារ [5] | $ 954 | $991 | $ 954 | $934 | **$929*** |

---

[2] ចំនួនទឹកប្រាក់ទូទាត់សម្រាប់SSI/SSPពិតប្រាកដ ត្រូវបានគេគណនា ដោយការដកពីចំណូលរបស់អ្នកចេញអត្រាទូទាត់ដែលមានចុះនៅក្នុងតារាងនេះ។

[3] រួមមានក្មេងពិការភ្នែកដែលមានអាយុក្រោម18ឆ្នាំ។

[4] អានីតិជនជាជនពិការមានអាយុក្រោម18ឆ្នាំដែលរស់នៅជាមួយឪពុកម្តាយ។ មិនរាប់បញ្ចូលក្មេងពិការភ្នែកទេ។ កម្រិតការទូទាត់SSP សម្រាប់កុមារពិការភ្នែក គឺដូចគ្នាទៅនឹងមនុស្សពេញវ័យដែលពិការភ្នែកដែរ។

[5] អាស្រ័យលើអត្រាSSPសម្រាប់ជនចាស់ជរា និង ពិការដោយមានបន្ថែមនូវជំនួយអាហារតាមភោជនីយដ្ឋាន (Restaurant Meals Allowance (RMA)) ស្មើ

| អត្រាទូទាត់សម្រាប់កម្មវិធីSSI/SSP—បុគ្គលដែលមានសិទ្ធិ | | | | | |
|---|---|---|---|---|---|
| | 1ធ្នូ 2008 | 1មករា 2009 | 1ឧសភា 2009 | 1កក្កដា 2009 | **1តុលា 2009** |
| អ្នករស់នៅCCF[6] | $1,049 | $1,086 | $1,086 | $1,086 | **$1,086** |

---

នឹង$84 សម្រាប់បុគ្គលម្នាក់ៗ និង $168 សម្រាប់ប្ដីប្រពន្ធ។ ថ្ងៃទី19 ខែកុម្ភៈ 2009 និង ថ្ងៃទី24 ខែកក្កដា 2009 ច្បាប់ស្ដីពីថវិការដ្ឋមិនបន្ថយចំនួនទឹកប្រាក់ $84 និង $168 សម្រាប់ RMA ទេ។ ចំនួនទឹកប្រាក់ទាំងនេះ ក៏នឹងមិនកើនឡើង នៅថ្ងៃទី1 ខែមករា ឆ្នាំ2009 ដែរ។

[6] កម្រិតទាំងនេះ គឺជាលទ្ធភាពសម្រប់តំហែទាំនៅតាមផ្ទះ (អាហារ និង តំហែទាំ) ដូចជាលទ្ធភាពតំហែទាំតាមសហគមន៍ លើកកម្ពស់គ្រួសារ ឬ ការបញ្ឆោក់អំពីគ្រួសារ។ វា មិនមែនជាលទ្ធភាពនៃតំហែទាំសុខភាពទេ និង មិនត្រូវបានគេ អនុញ្ញាតិដោយក្រសួងទទួលបន្ទុកតំហែទាំសុខភាពនៅរដ្ឋកាលីហ្វ័រញ៉ាទេ។ លទ្ធភាពទាំងនេះ បានពីចំនួនទឹកប្រាក់នៃ SSI សម្រាប់ផ្ដល់នូវអាហារ និង តំហែទាំ ដែលចាំបាច់ត្រូវផ្ដល់ឲ្យយ៉ាងហោចណាស់ចំនួន $125 ក្នុងមួយខែដល់អ្នកសម្រាប់ការចំណាយផ្ទាល់ខ្លួន និង ឥតព្រាងទុក។ មិនមានការប្រែប្រួលនៅក្នុងចំនួនទឹកប្រាក់ SSI ដែលចំណាយសម្រប់មនុស្សដែលរស់នៅក្នុងប្រភេទ លទ្ធភាពទាំងនេះទេ។

| អត្រាទូទាត់សម្រាប់កម្មវិធី**SSI/SSP—**បុគ្គលដែលមានសិទ្ធិ | | | | | |
|---|---|---|---|---|---|
| | 1ធ្នូ 2008 | 1មករា 2009 | 1ឧសភា 2009 | 1កក្កដា 2009 | **1តុលា 2009** |
| អ្នករស់នៅក្នុងលទ្ធភាពតំហែទាំរយៈពេលវែង (លទ្ធភាពព្យាបាល និង តំហែទាំរយៈពេលមធ្យម)[7] | $50 | $50 | $50 | $50 | **$50** |

[7] មានលទ្ធភាពនានានៃតំហែទាំសុខភាពដែលទទួលបានការអនុញ្ញាតិពីក្រសួងទទួលបន្ទុកតំហែទាំសុខភាព។ អ្នក ទទួលបាន$50 ក្នុងមួយខែសម្រាប់ការចំណាយផ្ទាល់ខ្លួន និង ឥតព្រាងទុក។ រហូតមកទល់ពេលនេះ មិនដែលមានតម្លៃស្វ័យប្រវត្តិមួយនៃការកែតម្រូវតាមការរស់នៅសម្រាប់អត្រានានានៃលទ្ធភាពផ្គត់ផ្គង់ថវិកាសម្រាប់ជំនួយលើតំហែទាំផ្ទែកពេទ្យទេ។

| អត្រាទូទាត់សម្រាប់ **SSI/SSP—គូស្វាមីភរិយាដែលមានសិទ្ធិ** | | | | | |
|---|---|---|---|---|---|
| | 1 ធ្នូ 2008 | 1 មករា 2009 | 1ឧសភា 2009 | 1 កក្កដា 2009 | **1 តុលា 2009** |
| ទាំងជនចាស់ជរា និង ពិការដែលរស់នៅផ្ទះ | $1,524 | $1,579 | $1,524 | $1,489 | **$1,407** |
| ទាំងជនពិការភ្នែកដែលរស់នៅផ្ទះ | $1,751 | $1,806 | $1,751 | $1,711 | **គ្មានព័ត៌មាន**[8] |
| ជនចាស់ជរា ឬ ពិការម្នាក់/ អ្នកពិការភ្នែកម្នាក់ដែលរស់នៅផ្ទះ | $1,666 | $1,721 | $1,666 | $1,628 | **គ្មានព័ត៌មាន** |
| អ្នកដែលរស់ផ្ទះដោយគ្មានលទ្ធភាពចម្អិនម្ហូបអាហារ[9] | $ 1,692 | $1,747 | $ 1,692 | $ 1,657 | **$1,575**[10] |

[8] ចំនួនទឹកប្រាក់នេះ នឹងត្រូវគេផ្សព្វផ្សាយនាពេលឆាប់ៗនេះ ដោយក្រសួងកិច្ចការសង្គម។

[9] អាស្រ័យលើអត្រាSSPសម្រាប់ជនចាស់ជរា និង ពិការដោយមានបន្ថែមនូវជំនួយអាហារតាមភោជនីយដ្ឋាន (Restaurant Meals Allowance (RMA)) ស្មើនឹង$84 សម្រាប់បុគ្គលម្នាក់ៗ និង $168 សម្រាប់ប្តីប្រពន្ធ។ ថ្ងៃទី19 ខែកុម្ភៈ 2009 និង ថ្ងៃទី24 ខែកក្កដា 2009 ច្បាប់ស្តីពីថវិការដ្ឋមិនបន្ថយចំនួនទឹកប្រាក់ $84 និង $168 សម្រាប់ RMA ទេ។

| អត្រាទូទាត់សម្រាប់ **SSI/SSP—គូស្វាមីភរិយាដែលមានសិទ្ធិ** | | | | | |
|---|---|---|---|---|---|
| | 1 ធ្នូ 2008 | 1 មករា 2009 | 1ឧសភា 2009 | 1 កក្កដា 2009 | **1 តុលា 2009** |
| ប្តីប្រពន្ធដែលរស់នៅមានលទ្ធភាពតំហែទាំក្រៅផ្ទះដែលមិនមែនផ្នែកពេទ្យ[11] | $2,098 | $2,172 | $2,172 | $2,172 | **$2,172** |
| ប្តីប្រពន្ធដែលរស់នៅមានលទ្ធភាពតំហែទាំព្យាបាលទទួលបានថវិកាសម្រាប់ជំនួយផ្នែកពេទ្យ[12] | $100 | $100 | $100 | $100 | **$100** |

---

[10] ចំនួនទឹកប្រាក់នេះ នឹងត្រូវគេផ្សព្វផ្សាយនាពេលឆាប់ៗនេះ ដោយក្រសួងកិច្ចការសង្គម។

[11] សូមមើលលេខយោងទី5។

[12] សូមមើលលេខយោងទី6។

**តើនឹងមានតម្លៃស្វ័យប្រវត្តិកែសម្រួលការរស់នៅសម្រាប់ SSI/SSP នៅបណ្តាឆ្នាំខាងមុខនេះទេ?**

កន្លងមក មានតម្លៃស្វ័យប្រវត្តិកែសម្រួលតាមការរស់នៅទាំងពីរដ្ឋ និងរដ្ឋាភិបាលសហព័ន្ធជារៀងរាល់ឆ្នាំសម្រាប់ SSI/SSP។ ជារឿយៗ រដ្ឋបានកាត់បន្ថយ ឬ ព្យួរតម្លៃកែសម្រួលតាមការរស់នៅទាំងនេះ នៅពេលកំពុងប្រឈមនឹងបញ្ហាថវិកា។

ច្បាប់សន្តិសុខសង្គមសហព័ន្ធ នៅតែតម្រូវជាចាំបាច់ឲ្យរដ្ឋាភិបាលសហព័ន្ធផ្តល់នូវតម្លៃកែសម្រួលតាមការរស់នៅសម្រាប់ SSI។ លើសពីនេះទៅទៀតនោះ ដោយចាប់ចូលជាធរមាន ឬ មានប្រសិទ្ធភាពពីថ្ងៃទី1 តុលា 2009 រដ្ឋកាលីហ្វ័រញ៉ា បានបំបិទចោលតម្លៃស្វ័យប្រវត្តិរបស់រដ្ឋសម្រាប់សម្រួលតាមការរស់នៅលើចំណែកទូទាត់របស់ខ្លួន។ រដ្ឋការនៃរដ្ឋកាលីហ្វ័រញ៉ា នឹងចាំបាច់ត្រូវប្រកាន់យកចំណាត់ការណ៍នៅឆ្នាំខាងមុខនេះដើម្បីឲ្យបញ្ហានេះប្រែប្រួល។

មនុស្សដែលរស់នៅក្នុងលទ្ធភាពនៃតំហែទាំសុខភាពក្រោមការផ្គត់ផ្គង់ថវិកាពីកម្មវិធី Medi-Cal នោះ មិនដែលមានសិទ្ធិសម្រាប់តម្លៃស្វ័យប្រវត្តិកែសម្រួលតាមការរស់នៅ។ ពួកគេ ទទួលបានចំនួនទឹកប្រាក់ដ៏តិចតួចមួយចំពោះប្រាក់សម្រាប់ការចំណាយ “ផ្ទាល់ខ្លួន និង ឥតព្រាងទុក” ពី SSI/SSP។

**តើការកាត់ SSI មានផលប៉ះពាល់ដល់មនុស្សដែលរស់នៅជាក្រុមមួយ/រស់នៅទទួលរបបអាហារ និង តំហែទាំសុខភាព តំហែទាំនៅផ្ទះ ឬ លទ្ធភាពដែលទ្រទ្រង់ថវិកាដោយ Medi-Cal ទេ?**

ទេ! អត្រាដែលកាត់ នឹងមិនប៉ះពាល់ដល់មនុស្សដែលរស់នៅជាក្រុម/របស់នៅ

ទទួលរបបអាហារ និង តំហែទាំសុខភាព តំហែទាំនៅផ្ទះ ឬ ប្រភេទលទ្ធភាពផ្សេងទៀតទេ។ បញ្ហានេះ មានលក្ខណៈពិតប្រាកដជាក់ស្តែងសម្រាប់ពួកគេទាំងនេះ ដូចជា ICF/DDs។

- អ្នកដែលរស់នៅជាក្រុម/ក្នុងលទ្ធភាពទទួលរបបអាហារ និង តំហែទាំសុខភាពទាំងនេះ នឹងទទួលបាននូវទឹកប្រាក់ដែលមានចុះនៅក្នុងតារាងខាងលើនេះ ដោយគ្មានការកាត់បន្ថយទេ។ ប្រាក់នេះ ត្រូវបានគេប្រើប្រាស់ដើម្បីទូទាត់ចំពោះលទ្ធភាពរបបអាហារ និង តំហែទាំដែលវាឆ្លងកាត់អ្នកទទួល SSI ដោយផ្ទាល់ទេ។ សូមមើលលេខយោងទី5។
- មនុស្សដែលរស់ក្នុងលទ្ធភាពតំហែទាំសុខភាពដែលផ្គត់ផ្គង់ថវិកាដោយ Medi-Cal នឹងបន្តទទួលតែប្រាក់សម្រាប់ការចំណាយផ្ទាល់ខ្លួន និង ឥតព្រាងទុកតែប៉ុណ្ណោះ។ សូមមើលលេខយោងទី6។

## ហេតុអ្វីទើបបានជាអត្រាទូទាត់សម្រាប់គ្រួសារប្តីប្រពន្ធនឹងថយចុះច្រើនជាអត្រាទូទាត់សម្រាប់បុគ្គលម្នាក់ៗ?

អភិបាលរដ្ឋ បានស្នើឲ្យរដ្ឋការខ្លួនកាត់បន្ថយចំណាយរបស់រដ្ឋសម្រាប់ SSI/SSP ចំពោះកម្រិតមធ្យមដាច់ខាតដែលរដ្ឋាភិបាលសហព័ន្ធនឹងអនុញ្ញាតិឲ្យមានការកាត់។ ដោយយោងទៅតាមក្រសួងកិច្ចការសង្គមនៃរដ្ឋកាលីហ្វ័រញ៉ា អត្រានេះមានតម្លៃជាទឹកប្រាក់ស្មើនឹង $830 សម្រប់បុគ្គលម្នាក់ៗដែលមានអាយុច្រើនជាង65ឆ្នាំ ឬ ជាអ្នកពិការ និង $1,407 សម្រាប់គ្រួសារប្តីប្រពន្ធ ទាំងអ្នកដែលមានអាយុច្រើនជាង65ឆ្នាំ ឬ ជាជនពិការ។ រដ្ឋការ មិនដំណើរការបញ្ហានេះស្របជាអភិបាលទាំងស្រុងទេ។ ផ្ទុយមកវិញ រដ្ឋការបានសម្រេចកាត់បន្ថយអត្រាទូទាត់លើអត្ថប្រយោជន៍សម្រាប់បុគ្គលម្នាក់ៗដល់ទៅ $845 (ដែលពីមុនមានត្រឹមតែ $830) ប៉ុន្តែបានទទួលយកសំណើរបស់អភិបាលដើម្បីកាត់បន្ថយអត្រា

ទូទាត់លើអត្ថប្រយោជន៍សម្រាប់ប្តីប្រពន្ធមកនៅត្រឹមកម្រិតមធ្យមដែលស្មើនឹង $1,407។

## តើខ្ញុំអាចដាក់ពាក្យប្តឹងតវាបានទេ ប្រសិនខ្ញុំគិតថាការកាត់ SSI/SSP នេះ មិនត្រឹមត្រូវ?

ផ្នែករដ្ឋបាលសន្តិសុខសង្គម និយាយថា ដោយសារការកាត់បន្ថយនៅលើមូលមូលប្បទានប័ត្ររបស់អ្នកដែលបានមកពីកំណែនៅក្នុងច្បាប់រដ្ឋដែលមានផលប៉ះពាល់លើអ្នករាល់គ្នាដូចជាអ្នកជាដើម អ្នកមិនមានសិទ្ធិប្តឹងឧទ្ធរណ៍សម្រាប់លទ្ធផលនៅក្នុងអត្ថប្រយោជន៍នានានោះទេ។ យ៉ាងណាមិញ អ្នកមានសិទ្ធិដាក់ពាក្យប្តឹងសាទុក្ខបាន ប្រសិនបើអ្នកជឿជាក់ថា SSA បានបង្កើតឲ្យមានកំហុសនៅក្នុងរបៀបគណនាទឹកប្រាក់ត្រូវកាត់។ ឧទាហរណ៍: បើច្បាប់ថ្មីនិយាយថា អ្នកត្រូវទទួលបានការកាត់តាមការអនុញ្ញាតិសម្រាប់ SSI/SSP ស្មើនឹង $5 ប៉ុន្តែការទូទាត់របស់អ្នកត្រូវបានគេកាត់បន្ថយយ៉ាងពិតប្រាកដរហូតដល់ $75.00 បន្ទាប់មកអ្នកនឹងមានសិទ្ធិស្នើសុំឲ្យមានសវនាការសើរើមួយឡើងវិញ។

## តើខ្ញុំនឹងមានការទូទាត់លើសមួយទេ ប្រសិនបើខ្ញុំប្តឹងសាទុក្ខ?

បើអ្នកបានស្នើថា អត្ថប្រយោជន៍នានារបស់អ្នកបន្តប្រព្រឹត្តទៅតាមកម្រិតកន្លងមក (នោះគឺចំនួនទឹកប្រាក់ដែលបានកំពុងតែទទួលនៅមុនមានការកាត់) ហើយអ្នកចាញ់ការប្តឹងសាទុក្ខរបស់អ្នកៗនឹងត្រូវមានការទូទាត់មួយលើសនេះមែន។[13]

---

[13] សូមមើលផ្នែកទី20 CFR §§ 416.1402, 416.1403, 416.1401

**ឥឡូវនេះ មូលប្បទានប័ត្រ SSI របស់ខ្ញុំ កំពុងត្រូវបានគេកាត់បន្ថយដើម្បីការទាញយកការទូទាត់លើសមួយ។ តើនឹងមានអ្វីកើតមានឡើង ពេលឥឡូវនេះ?**

បើអ្នកទទួលបាន SSI នោះ ផ្នែកសន្តិសុខសង្គមមិនអាចកាត់ឲ្យលើសពី10% នៃអត្រាទូទាត់អត្ថប្រយោជន៍ SSI ដែលបានពីមូលប្បទានប័ត្ររបស់អ្នកដែលនឹងទាញយកការទូទាត់លើស ឬ បន្ថែមនេះបានទេ។ ដោយសារអត្រានសការទូទាត់ SSI/SSP កំពុងថយចុះ ផ្នែកសន្តិសុខសង្គមកាត់ដើម្បីបង្គ្រប់ចំណាយបន្ថែមនេះ ក៏ត្រូវថយចុះទៅតាមនោះដែរ។ ចំនួនទឹកប្រាក់ដែលផ្នែកសន្តិសុខសង្គមកាត់បានពីមូលប្បទានប័ត្ររបស់អ្នក ត្រូវថយចុះ10% នៃអត្រាទូទាត់អត្ថប្រយោជន៍ SSI ថ្មី។

**តើ DRC បានធ្វើអ្វីខ្លះនៅពេលការកាត់ទាំងនេះ ត្រូវបានគេស្នើឡើង?**

បណ្តាញការពារសិទ្ធិជនពិការនៃរដ្ឋកាលីហ្វ័រញ៉ា (DRC) បានស្នើឲ្យមាននូវការកាត់ទាំងអស់នេះ។ វាបានចូលជាធរមានលើការប្រឆាំងរបស់យើង និង ការប្រឆាំងជាច្រើនទៀតរបស់ក្រុមមេធាវី។ យើងខ្ញុំ មានការខកចិត្តយ៉ាងខ្លាំងដែលថា ការកាត់ទាំងនេះបានចូលជាធរមានហើយ។ បញ្ហាទាំងនេះ នឹងបង្កើតឲ្យមានភាពទីទាល់ក្រដល់ប្រជាពលរដ្ឋជាច្រើ។